ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកោះកុង
សំណុំរឿងព្រហ្មទណ្ឌលេខ ១៨១
ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១
សាលក្រមព្រហ្មទណ្ឌ
លេខៈ ៨០ "ឥ"
ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកោះកុង

បានបើកសវនាការជាសាធារណៈនៅសាលជំនុំជម្រះនៃសាលាដំបូងខេត្តកោះកុងនាថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ០៨:៣០នាទី ដោយមានសមាសភាពដូចតទៅៈ

## ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ប្រធានសាលាដំបូងខេត្តកោះកុង

## ចៅក្រមប្រឹក្សា

-លោក [redacted] អនុប្រធានសាលាដំបូងខេត្តកោះកុង

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តកោះកុង

## តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកោះកុង

## ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកោះកុង

## មេធាវីការពារក្តី

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ដើម្បីជំនុំជម្រះ លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៨១ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ ដែលមានជនជាប់ចោទៈ

១-ឈ្មោះ [redacted] វុត្ថា ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ គ្មាន កំរិតវប្បធម៌ ថ្នាក់ទី៨ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកោះកុង ទីលំនៅបច្ចុប្បន្ននៅភូ [redacted] ខេត្តកោះកុង ឪពុកឈ្មោះ [redacted] ធន់ (រ) ម្តាយឈ្មោះ [redacted] ចំរើន (រ) ជាអនីតិជន ទោសពីមុន គ្មាន(ឃុំខ្លួនថ្ងៃទី០៧-០៤-២០២១)។

២-ឈ្មោះ [redacted] តុលា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ សិស្ស កំរិតវប្បធម៌ ថ្នាក់ទី៧ ទីកន្លែងកំណើត និង ទីលំនៅបច្ចុប្បន្ននៅភូ [redacted] ខេត្តកោះកុង ឪពុកមិនស្គាល់ឈ្មោះ (ស) ម្តាយឈ្មោះ [redacted] ចន្ទី(រ) ជាអនីតិជន ទោសពីមុន គ្មាន ។ (ឃុំខ្លួនថ្ងៃទី០៧-០៤-២០២១)។

៣-ឈ្មោះ [redacted] ប៊ុនថាំ *ហៅ*ប៉ិត ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ សិស្ស កំរិតវប្បធម៌ ថ្នាក់ទី១០ មានទីកន្លែងកំណើតភូមិ [redacted] ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្នភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ឪពុកឈ្មោះ [redacted] ប៊ុនធឿន (ស) ម្តាយឈ្មោះ [redacted] ថៃ (រ) ជាអនីតិជន ទោសពី មុន គ្មាន ។ (ឃុំខ្លួនថ្ងៃទី០៧-០៤-២០២១) ។

៤-ឈ្មោះ [redacted] ចាវ ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ សិស្ស កំរិតវប្បធម៌ ថ្នាក់ទី៩ មានទីកន្លែងកំណើត និង ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកោះកុង ឪពុកឈ្មោះ [redacted] តឹម (រ) ម្តាយឈ្មោះ [redacted] សុខា (រ) ជាអនីតិជន ទោសពីមុន គ្មាន ។

- (ឃុំខ្លួនថ្ងៃទី០៧-០៤-២០២១) ។

៥-ឈ្មោះ [redacted] សើគីរ៉ែន *ហៅ*លីន ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ សិស្ស កំរិតវប្បធម៌ ថ្នាក់ទី១០ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកោះកុង ឪពុកឈ្មោះ [redacted] កូប (រ) ម្តាយឈ្មោះ [redacted] វ៉ូនី (រ) ជាអនីតិជន ទោសពីមុន គ្មាន ។ (ឃុំខ្លួនថ្ងៃទី០៧-០៤-២០២១)។

<u>*ជាប់ចោទពីបទ:*</u> ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ និងមានមនុស្សច្រើនក្នុងឋានៈជាចារី និងសហចារី ប្រព្រឹត្តនៅចំណុចសួនច្បារមាត់សមុទ្រ ស្ថិតនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២១៨ ចំណុច២ , ៣ នៃក្រមព្រហ្មទណ្ឌ ។

**<u>ដើមបណ្តឹងរដ្ឋប្បវេណី:</u>**

-ឈ្មោះ [redacted] សារិទ្ធិ ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ រស់នៅភូមិ០១ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ។ (អវត្តមាន) ។

-<u>បានឃើញ</u>:ដីកាសន្និដ្ឋានស្ថាពរលេខ: ១២៨ អ.យ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកោះកុង ។

<u>-បានឃើញ</u>:ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ១៤៦២ តព/២១ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកោះកុង ។

<u>-បានឃើញ</u>:ដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ: ១៦៣ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តកោះកុង ។

**<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:</u>**

-កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង១៧:៣០នាទី ស្ថិតនៅចំណុចសួនច្បារមាត់សមុទ្រ ស្ថិតនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានករណី ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ០១ បានកើតឡើង ដែលបង្កដោយជនសង្ស័យចំនួន០៦នាក់ រួមមានឈ្មោះ [redacted] វុត្ថា ឈ្មោះ [redacted] តុលា , ឈ្មោះ [redacted] ប៊ុនថាំ *ហៅ*ប៉ែត , ឈ្មោះ [redacted] ចាវ , ឈ្មោះ [redacted] សើគីរ៉ែន *ហៅ*លីន និងឈ្មោះខ្លា បានធ្វើសកម្មភាពដោយជិះម៉ូតូចំនួន០៣គ្រឿង ប្រដាប់ដោយកាំបិតផ្គាក់ចំនួន០១ដើម និងកាំបិតប៉ាំងតោចំនួន០១ដើម ដេញកាប់ទៅលើក្រុមរបស់ឈ្មោះ [redacted] សារិទ្ធិ ប៉ុន្តែមិនបានបង្ករបួសស្នាមដល់ជនរងគ្រោះនោះទេ ដោយសាសមត្ថកិច្ចទៅទាន់ ធ្វើឲ្យក្រុមជនសង្ស័យនាំគ្នារត់បាត់អស់ ដោយបន្សល់ទុកវត្ថុតាងរួមមានម៉ូតូចំនួន០១គ្រឿង កាំបិតផ្គាក់ចំនួន០១ដើម និងកាំបិតប៉ាំងតោចំនួន០១ដើម នៅនឹងកន្លែងកើតហេតុ ។

**<u>នាពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ [redacted] វុត្ថា បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២១ វេលាម៉ោងប្រហែលជា ០៥ល្ងាច ខ្លួនបានជិះម៉ូតូទៅលេងមាត់សមុទ្រ (កន្លែងស្តូបគល់ស្ពានកោះកុង) រួមមានឈ្មោះ [redacted] តុលា , ឈ្មោះ [redacted] សើគីរ៉ែន *ហៅ*លីន , ឈ្មោះ [redacted] ប៊ុនថាំ *ហៅ*ប៉ែត , ឈ្មោះ [redacted] ចាវ និងឈ្មោះ ខ្លា ពេលពួកខ្លួនអង្គុយលេងរហូតដល់ម៉ោងប្រហែល ១៧:៣០នាទីល្ងាច ក៏បានឃើញឈ្មោះ [redacted] សារិទ្ធិ អង្គុយលេងនៅ

ក្បែរស្តូបមិត្តភាពកម្ពុជា-វៀតណាម (គល់ស្ពានកោះកុង) ពេលនោះឈ្មោះ ខ្លា បានបបួលពួកខ្លួនទៅសុំបារីឈ្មោះ [redacted] សារិទ្ធិ ហើយឈ្មោះ [redacted]សារិទ្ធិ ឆ្លើយថាៈ គ្មានបារីទេ ពេលនោះពួកខ្លួនក៏បានរើសដុំថ្មគប់ទៅលើឈ្មោះ [redacted]សារិទ្ធិៗ ក៏បានស្រែកជេរឪដងមកលើក្រុមរបស់ខ្លួន ភ្លាមនោះខ្លួន និងបក្សពួកក៏បានជិះម៉ូតូទៅយកកាំបិតនៅក្នុងបន្ទប់ជួលរបស់ខ្លួនចំនួន ០២ដើម (កាំបិតផ្គាក់០១ និងកាំបិតប៉ុងតោ០១) ហើយជិះត្រឡប់មកកន្លែងដើមវិញ ដើម្បីមកកាប់លើឈ្មោះ [redacted] សារិទ្ធិ ដែលបានជេរឪដងដាក់ពួកខ្លួន ពេលឃើញឈ្មោះ [redacted] សារិទ្ធិ កំពុងអង្គុយលេង ពួកខ្លួនក៏បានទាញកាំបិតចេញពីក្នុងដៃអាវបម្រុងកាប់ស្រាប់តែសមត្ថកិច្ចមកដល់ ខ្លួនក៏បានបោះកាំបិតចោល រួចហើយជិះម៉ូតូទៅបន្ទប់ជួលរបស់ខ្លួននៅម្តុំស្មាច់ង៉ាម សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ជាមួយឈ្មោះ [redacted] តុលា និងឈ្មោះ [redacted] សើគីរីន ហៅលីន ហើយសំងំដេកទល់ភ្លឺតែម្តង ។ កន្លងមកខ្លួនមិនដែលធ្លាប់ស្គាល់ឬមានទំនាស់អ្វីជាមួយឈ្មោះ [redacted] សារិទ្ធិ ទេ ។ លុះព្រឹកឡើងថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ០៩ព្រឹក ខ្លួន និងឈ្មោះ [redacted] តុលា និងឈ្មោះ [redacted] ថាវ បាននាំគ្នាទៅលេងទឹកជ្រោះ២៩៧ ពេលត្រឡប់មកវិញ ក៏បានជួបនឹងសមត្ថកិច្ចតាមផ្លូវ ហើយធ្វើការឃាត់ខ្លួនតែម្តង ។

-ជនជាប់ចោទឈ្មោះ [redacted] តុលា បានឆ្លើយបញ្ជាក់ថាៈ កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ០៩ល្ងាច ខ្លួនបានជិះម៉ូតូចេញពីផ្ទះនៅភូមិ-ឃុំទួលគគីរ ស្រុកមណ្ឌលសីមា ខេត្តកោះកុង ដោយជិះមកលេងនៅម្តុំផ្ទះក្រហម មានគ្នា ០៣នាក់ ឈ្មោះ [redacted] ថាវ , ឈ្មោះ [redacted] វុត្ថា និងរូបខ្លួន ។ ក្រោយមករូបខ្លួនក៏បានជិះម៉ូតូបន្តទៅលេងមាត់សមុទ្រ (កន្លែងស្តូបគល់ស្ពានកោះកុង) រួមមានឈ្មោះ [redacted] វុត្ថា , ឈ្មោះ [redacted] សើគីរីន ហៅលីន , ឈ្មោះ [redacted] ប៊ុនថាំ ហៅប៉ែត , ឈ្មោះ [redacted] ថាវ និងឈ្មោះ ខ្លា ពេលនោះឈ្មោះ ខ្លា ក៏បានបបួលពួកខ្លួនទៅសុំបារីពីឈ្មោះ [redacted] សារិទ្ធិ ដែលអង្គុយលេងនៅក្បែរគ្នា ហើយឈ្មោះណរាវ សារិទ្ធិ ឆ្លើយថាៈ គ្មានបារីទេ ពេលនោះពួកខ្លួនក៏បានរើសដុំថ្មគប់ទៅលើឈ្មោះ [redacted] សារិទ្ធិៗ ក៏បានស្រែកជេរឪដងមកលើក្រុមរបស់ខ្លួន ភ្លាមនោះខ្លួន និងបក្សពួកក៏បានជិះម៉ូតូទៅយកកាំបិតនៅក្នុងបន្ទប់ជួលរបស់ឈ្មោះ [redacted] វុត្ថា នៅម្តុំស្មាច់ង៉ាម សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ពេលយកបានកាំបិតចំនួន ០២ដើម (កាំបិតផ្គាក់០១ និងកាំបិតប៉ុងតោ០១) ហើយជិះត្រឡប់មកកន្លែងដើមវិញ ដើម្បីមកកាប់លើឈ្មោះ[redacted] សារិទ្ធិ ដែលបានជេរឪដងដាក់ពួកខ្លួន តែមិនទាន់បានកាប់ផង ស្រាប់តែសមត្ថកិច្ចមកដល់ ខ្លួនក៏បានលោតចេញពីម៉ូតូរត់គេចខ្លួនទៅសំងំដេកនៅផ្ទះជួលទល់ភ្លឺ ។ លុះព្រឹកឡើងថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ០៩ព្រឹក រូបខ្លួន , ឈ្មោះ [redacted] វុត្ថា និងឈ្មោះ [redacted] សើគីរីន ហៅលីន បាននាំគ្នាទៅលេងទឹកជ្រោះ ២៩៧ ពេលត្រឡប់មកវិញ ក៏បានជួបនឹងសមត្ថកិច្ច ហើយធ្វើការឃាត់ខ្លួនតែម្តង ។

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនថាំ ហៅ ប៉ែត បានឆ្លើយបញ្ជាក់ថាៈ កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ០៩ល្ងាច ខ្លួនកំពុងជិះម៉ូតូជាមួយឈ្មោះ ចុង ស្រាប់តែឃើញឈ្មោះ [redacted] តុលា , ឈ្មោះ [redacted] សើគីរីន ហៅលីន , ឈ្មោះ [redacted] វុត្ថា , ឈ្មោះ [redacted] ថាវ និងឈ្មោះ ខ្លា កំពុងជិះម៉ូតូនៅមាត់សមុទ្រ (កន្លែងស្តូបគល់ស្ពានកោះកុង) ខ្លួនក៏បានជិះម៉ូតូចូលទៅជាមួយពួកគេ ពេលនោះឈ្មោះ ខ្លា បានទៅសុំបារីពីឈ្មោះ [redacted] ថារិទ្ធ ភ្លាមនោះស្រាប់តែឃើញក្រុមបក្សពួករបស់ឈ្មោះខ្លា បានយកដុំថ្មគប់ទៅលើឈ្មោះ [redacted] សារិទ្ធិ បន្ទាប់មកខ្លួន និងក្រុមបក្សពួករបស់ឈ្មោះ ខ្លា ទាំងអស់គ្នា ក៏បានជិះម៉ូតូចេញ ហើយក្រុមឈ្មោះ ខ្លា ក៏បានជិះម៉ូតូទៅយកកាំបិតនៅម្តុំផ្ទះជួលនៅស្មាច់ង៉ាម ចំណែកពួកខ្លួន ០៣នាក់ នៅចាំក្បែរវិទ្យាល័យកោះកុង ពេលក្រុមឈ្មោះ ខ្លា យកកាំបិតបានហើយ ក៏បានបានមកជុំគ្នា ហើយជិះម៉ូតូទៅកន្លែងដើមវិញ ដើម្បីកាប់ទៅលើឈ្មោះ [redacted] សារិទ្ធិ តែមិនទាន់បានកាប់ផង ស្រាប់តែសមត្ថកិច្ចមកដល់ ពួកខ្លួនក៏បានជិះម៉ូតូរត់គេចខ្លួន



Scanned with CamScanner

រៀងៗខ្លួន ។ លុះដល់ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ ខ្លួនបានគេចទៅសំងំនៅភូមិ-ឃុំទួលគគីរ ស្រាប់តែម៉ោងប្រហែល ១០យប់ សមត្ថកិច្ចបានតាមរកខ្លួនឃើញ ក៏នាំមកអធិការដ្ឋាននគរបាលក្រុងខេមរភូមិន្ទវិញ ។

-ជនជាប់ចោទឈ្មោះ [redacted] ថាវ បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ០៥ល្ងាច ឈ្មោះ ខ្លា បានជិះម៉ូតូមកហៅខ្លួនដល់ផ្ទះដោយមានភ្ជាប់ជាមួយកាំបិតប៉ុងតោចំនួន ០១ដើម និងកាំបិតផ្គាកចំនួន០១ដើម ដោយប្រាប់ថាទៅលេងមាត់សមុទ្រ លុះទៅដល់មាត់សមុទ្រ (កន្លែងស្តូបគល់ស្គាន) ឈ្មោះ ខ្លា បានឈប់ម៉ូតូ ។ ហើយខ្លួន និងឈ្មោះ ខ្លា បានកាន់កាំបិត ដើរចូលទៅកាប់ឈ្មោះ [redacted] សារិទ្ធិ តែមិនទាន់បានកាប់ផង ក៏ត្រូវសមត្ថកិច្ចមកដល់ ហើយខ្លួនក៏បានបោះកាំបិតចោល ហើយជិះម៉ូតូទៅបន្ទប់ជួលនៅស្មាច់ង៉ាម ជាមួយឈ្មោះ [redacted] តុលា និងឈ្មោះ [redacted] សើគីរីន *ហ*លីន សំងំដេកទល់ភ្លឺ ។ លុះព្រឹកឡើងថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ០៩ព្រឹក រូបខ្លួន , ឈ្មោះ [redacted] តុលា និងឈ្មោះ [redacted] វុត្ថា បាននាំគ្នាទៅលេងទឹកជ្រោះ២៩៧ ពេលត្រឡប់មកវិញ ក៏បានជួបនឹងសមត្ថកិច្ចតាមផ្លូវ ហើយធ្វើការឃាត់ខ្លួនតែម្តង ។ ចំពោះរឿងក្រុមឈ្មោះ ខ្លា សុំបារីឈ្មោះ ណាវ សារិទ្ធិ ហើយគេមិនឲ្យ រួចហើយកដុំថ្មគប់ទៅលើគេនោះ ខ្លួនពុំបានដឹងទេ ។ កន្លងមកខ្លួនដែលស្គាល់ ឬមានទំនាក់ទំនងជាមួយឈ្មោះ [redacted] សារិទ្ធិ នោះទេ ។

-ជនជាប់ចោទឈ្មោះ [redacted] សើគីរីន *ហ* លីន បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ០៥ល្ងាច ឈ្មោះ ខ្លា បានជិះម៉ូតូមកហៅខ្លួនដល់ផ្ទះដោយមានភ្ជាប់ជាមួយកាំបិតប៉ុងតោចំនួន ០១ដើម និងកាំបិតផ្គាកចំនួន០១ដើម ដោយប្រាប់ថាទៅលេងមាត់សមុទ្រ លុះទៅដល់មាត់សមុទ្រ (កន្លែងស្តូបគល់ស្គាន) ឈ្មោះ ខ្លា បានឈប់ម៉ូតូ ។ ហើយខ្លួន និងឈ្មោះ ខ្លា បានកាន់កាំបិត ដើរចូលទៅកាប់ឈ្មោះ [redacted] សារិទ្ធិ តែមិនទាន់បានកាប់ផង ក៏ត្រូវសមត្ថកិច្ចមកដល់ ហើយខ្លួនក៏បានបោះកាំបិតចោល ហើយជិះម៉ូតូទៅបន្ទប់ជួល នៅស្មាច់ង៉ាម សំងំដេកទល់ភ្លឺ ។ លុះព្រឹកឡើងថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ០៦ល្ងាច សមត្ថកិច្ចបានហៅខ្លួនមកអធិការដ្ឋាននគរបាលក្រុងខេមរភូមិន្ទ មកសាកសួរ ហើយធ្វើការឃាត់ខ្លួន រូបខ្លួនតែម្តង ។ ចំពោះរឿងក្រុមឈ្មោះ ខ្លា សុំបារីឈ្មោះ [redacted] សារិទ្ធិ ហើយគេមិនឲ្យ រួចហើយកដុំថ្មគប់ទៅលើគេនោះ ខ្លួន ពុំបានដឹងទេ ។ កន្លងមកខ្លួនដែលស្គាល់ ឬមានទំនាក់ទំនងជាមួយឈ្មោះ [redacted] សារិទ្ធិ នោះទេ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារិទ្ធ (អវត្តមានក្នុងនិតិវិធី) ។

-តំណាងអយ្យការនាពេលសវនាការបានធ្វើសេចក្តីសន្និដ្ឋានទោសថា: មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] វុត្ថា, ឈ្មោះ [redacted] តុលា , ឈ្មោះ [redacted] ប៊ុនថាំ *ហ* ប៉ែត , ឈ្មោះ [redacted] ថាវ និងឈ្មោះ [redacted] សើគីរីន *ហ* លីន *ពីបទ:* ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ និងមានមនុស្សច្រើនក្នុងឋានៈជាចារី និងសហចារី ប្រព្រឹត្តនៅចំណុចសួនច្បារមាត់សមុទ្រ ស្ថិតនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃ ចំណុច២,៣ នៃក្រមព្រហ្មទណ្ឌ តាងនាមតំណាងអយ្យការសូមរក្សាបទចោទប្រកាន់ទុកជាបានការពេញទាំងមូលដដែល តាមដីកាសន្និដ្ឋានស្ថាពរលេខ ១២៨ អ.យ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ និងស្នើសុំឲ្យតុលាការពិនិត្យ និងពិចារណា សម្រេចតាមច្បាប់ ។

-លោកស្រី [redacted] ជាមេធាវីការពារក្តីបានធ្វើសេចក្តីសន្និដ្ឋាន: កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១៧:៣០នាទីល្ងាច នៅចំណុចសួនច្បារមាត់សមុទ្រ ស្ថិតនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានករណីអំពើហិង្សាមួយ បានកើតឡើង បង្កដោយជនសង្ស័យចំនួន ០៦នាក់ មានឈ្មោះ [redacted] វុត្ថា, ឈ្មោះ [redacted] តុលា , ឈ្មោះ [redacted] ប៊ុនថាំ *ហ* ប៉ែត , ឈ្មោះ [redacted] ថាវ និងឈ្មោះ [redacted]

សើគីរីន និងឈ្មោះ ខ្លា ភេទប្រុស អាយុប្រហែល ១៧ឆ្នាំ (រត់គេចខ្លួន) បានធ្វើសកម្មភាពដោយជិះម៉ូតូចំនួន ០៣គ្រឿង ប្រដាប់ដោយកាំបិតផ្គាក់ ចំនួន ០១ដើម និងកាំបិតប៉ុងតោ ចំនួន ០១ដើម ដេញកាប់ទៅលើក្រុមរបស់ឈ្មោះ [redacted] សារិទ្ធិ ភេទប្រុស អាយុ ២៣ឆ្នាំ ប៉ុន្តែមិនបានបង្កឲ្យមានរបួសស្នាមដល់ជនរងគ្រោះនោះទេ ដោយសារសមត្ថកិច្ចទៅទាន់ ធ្វើឲ្យជនសង្ស័យនាំគ្នារត់បាត់អស់ ដោយបន្សល់ទុកវត្ថុតាងរួមមានៈ ម៉ូតូ ចំនួន ០១គ្រឿង , កាំបិតផ្គាក់ ចំនួន ០១ដើម និងកាំបិតប៉ុងតោ ចំនួន ០១ដើម នៅនឹងកន្លែងកើតហេតុដែរ ។ កូនក្តីខ្លួនទាំង ០៥នាក់ បានសារភាពថាៈ ពួកខ្លួនពិតជាមានបំណងយកកាំបិតទៅកាប់ជនរងគ្រោះពិតមែន ប៉ុន្តែមិនទាន់បានកាប់ផង ក៏ត្រូវសមត្ថកិច្ចមកទាន់ ហើយពួកខ្លួនបានរត់គេចខ្លួនបាត់ ។ យ៉ាងណាមិញកាំបិតផ្គាក់ ចំនួន ០១ដើម និងកាំបិតប៉ុងតោ ចំនួន ០១ដើម នោះ គឺឈ្មោះ ខ្លា ជាអ្នកយកមក និងជាអ្នកដែលមានទំនាស់ ហើយមានបំណងយកមកកាប់ជនរងគ្រោះនោះទេ ។ ពួកកូនក្តីខ្លួនទាំង ០៥នាក់ មិនបានប្រើប្រាស់អំពើហិង្សាដោយកាប់ទៅលើជនរងគ្រោះទេ ហើយជនរងគ្រោះក៏មិនមានទទួលរងគ្រោះថ្នាក់អ្វីដែរ ។ កូនក្តីខ្លួនទាំង ០៥នាក់ បានសារភាពថា ពួកខ្លួនពិតជាប្រព្រឹត្តកំហុសដែលជឿតាមមិត្តភក្តិ ទៅប្រព្រឹត្តទង្វើបែបនេះហើយ ពួកគេក៏បានសារភាពនៅគ្រប់ដំណាក់កាលទាំងអស់ និងព្រមទទួលស្គាល់ទង្វើរបស់ខ្លួន ។ កូនក្តីខ្លួនពិតជាបានដឹងកំហុស និងសន្យាថាពួកខ្លួននឹងកែប្រែខ្លួនក្លាយជាបុគ្គលល្អក្នុងសង្គម ដោយសារតែខ្លួនបានរាងចាលហើយ ។ ម្យ៉ាងវិញទៀត ពួកគេសុទ្ធតែជាអនីតិជន អាយុក្រោម ១៨ឆ្នាំ ដែលមានការខ្វះខាតក្នុងការគិតពិចារណា ទើបបណ្តាលឲ្យដើរផ្លូវខុស សេពគប់មិត្តភក្តិមិនល្អ ហើយពួកគេក៏កំពុងតែស្ថិតនៅក្នុងវ័យសិក្សារៀនសូត្រ ។ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទទាំង ០៥នាក់ បានសំណូមពរ សុំឲ្យតុលាការបេត្តាផ្តល់នូវស្ថានសម្រាលទោសដល់កូនក្តីខ្លួន ដោយសារពួកគេបានដឹងកំហុស ទទួលស្គាល់កំហុស សោកស្តាយនូវទង្វើរបស់ខ្លួន និងសន្យាថា កែប្រែខ្លួន ។ លើសពីនេះទៅទៀតដោយសារពួកកូនក្តីខ្លួនមិនដែលធ្លាប់មានទោសពីមិនមកនោះទេ ដើម្បីឲ្យពួកគេឆាប់បានត្រឡប់ទៅសិក្សារៀនសូត្រវិញ និងធ្វើជាទំពាំងស្នងឬស្សីជូនជាតិ និងធ្វើជាបុគ្គលល្អសម្រាប់សង្គម និងគ្រួសារ ។

-ជនជាប់ចោទឈ្មោះ [redacted] វុត្ថា, ឈ្មោះ [redacted] តុលា , ឈ្មោះ [redacted] ប៊ុនថាំ *ហ* ប៉េត , ឈ្មោះ [redacted] ថាវ និងឈ្មោះ [redacted] សើគីរីន បាននិយាយសំដី និងសំណូមពរចុងក្រោយបង្អស់ប្រហាក់ប្រហែលគ្នាថាៈ ពួកខ្លួនសុំឲ្យតុលាការ មេត្តាជួយបន្ធូរបន្ថយទោឲ្យពួកខ្លួនផងដើម្បីឲ្យពួកខ្លួនបានចូលរួមរស់នៅក្នុងសង្គមវិញ ព្រោះពួកខ្លួនដឹងកំហុសហើយ ឈប់ប្រព្រឹត្តអំពើខុសឆ្គងបែបនេះទៀតហើយ ។

- ក្រោយពីបានស្តាប់ចម្លើយជនចាប់ចោទទាំង ០៥នាក់
- ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារផ្សេងៗក្នុងសំណុំរឿង
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានស្តាប់សំដី និងសំណូមពរចុងក្រោយបង្អស់របស់ជនជាប់ចោទ

**<u>សាលាដំបូងខេត្តកោះកុង</u>**

**ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយក្រុមប្រឹក្សាជំនុំជម្រះ**

**<u>យល់ឃើញថាៈ</u>**

-កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១៧:៣០នាទី ស្ថិតនៅចំណុចសួនច្បារមាត់សមុទ្រ ស្ថិតនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានករណី ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស មួយបានកើតឡើង ដែលបង្កដោយជនសង្ស័យចំនួន ០៦នាក់ រួមមានឈ្មោះ [redacted] វុត្ថា

ឈ្មោះ [redacted] តុលា , ឈ្មោះ [redacted] ប៊ុនថាំ ហៅប៉ិត , ឈ្មោះ [redacted] ថាវ , ឈ្មោះ [redacted] សើគីរីន ហៅលីន និងឈ្មោះ ខ្លា បានធ្វើសកម្មភាពដោយជិះម៉ូតូចំនួន០៣គ្រឿង ប្រដាប់ដោយកាំបិតផ្គាក់ចំនួន០១ដើម និងកាំបិតប៉ុងតោចំនួន០១ដើម ដេញកាប់ទៅលើក្រុមរបស់ឈ្មោះ [redacted] សារិទ្ធិ ប៉ុន្តែមិនបានបង្ករបួសស្នាមដល់ជនរងគ្រោះនោះទេ ដោយសាសមត្ថកិច្ចទៅទាន់ ធ្វើឲ្យក្រុមជនសង្ស័យនាំគ្នារត់បាត់អស់ ដោយបន្សល់ទុកវត្ថុតាងរួមមានម៉ូតូចំនួន០១គ្រឿង កាំបិតផ្គាក់ចំនួន០១ដើម និងកាំបិតប៉ុងតោចំនួន០១ដើម នៅនឹងកន្លែងកើតហេតុផងដែរ ក្រោមកសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកសាលាដំបូង និងឃុំខ្លួនរហូតសព្វថ្ងៃនេះ ។

-តាមចម្លើយរបស់ជនជាប់ចោទនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ , ចំពោះមុខអយ្យការ , ចំពោះមុខចៅក្រមស៊ើបសួរ និងចំពោះមុខតុលាការនាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] វុត្ថា, ឈ្មោះ [redacted] តុលា , ឈ្មោះ [redacted] ប៊ុនថាំ ហៅ ប៉ិត , ឈ្មោះ [redacted] ថាវ និងឈ្មោះ [redacted] សើគីរីន សុទ្ធតែឆ្លើយប្រហាក់ប្រហែលគ្នាថា: កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១៧:៣០នាទីល្ងាច ពួកខ្លួនទាំងអស់គ្នាពិតជាបានយកកាំបិតដាក់តាមខ្លួនបំរុងកាប់ទៅលើឈ្មោះ [redacted] សារិទ្ធិ តែពួកខ្លួនមិនទាន់បានកាប់ទៅលើឈ្មោះ [redacted] សារិទ្ធិ ផង ក៏ត្រូវសមត្ថកិច្ចមកដល់ ហើយក៏នាំគ្នារត់គេចខ្លួនទៅសំងំដេកនៅផ្ទះទាំងអស់គ្នាប្រាកដមែន ។ ចម្លើយនេះអាចឲ្យតុលាការយកជាការបាន ដើម្បីកំណត់ថា: ជនជាប់ចោទទាំងអស់ខាងលើនេះ ពុំទាន់បានប្រព្រឹត្តបទល្មើសនៅឡើយទេ ហើយក៏ពុំទាន់បានធ្វើឲ្យប៉ះពាល់ដល់រូបរាងកាយ ឬខូចខាតព្យសនកម្មដល់អ្នកដទៃនៅឡើយដែរ ។

-តាមសេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ បានទុកសិទ្ធិជូនក្រុមប្រឹក្សាជំនុំជម្រះ ពិនិត្យ និងពិចារណា សម្រេចតាមច្បាប់ ។

-គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] វុត្ថា, ឈ្មោះ [redacted] តុលា, ឈ្មោះ [redacted] ប៊ុនថាំ ហៅ ប៉ិត , ឈ្មោះ [redacted] ថាវ និងឈ្មោះ [redacted] សើគីរីន ហៅ លី ពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ និងមានមនុស្សច្រើនក្នុងឋានៈជាចារី និងសហចារី ប្រព្រឹត្តនៅចំណុចសួនច្បារមាត់សមុទ្រ ភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃ ចំណុច២,៣ នៃក្រមព្រហ្មទណ្ឌ ឡើយ ។ គប្បីតុលាការឲ្យជនជាប់ចោទឈ្មោះ [redacted] វុត្ថា, ឈ្មោះ [redacted] តុលា, ឈ្មោះ [redacted] ប៊ុនថាំ ហៅ ប៉ិត , ឈ្មោះ [redacted] ថាវ និងឈ្មោះ [redacted] សើគីរីន ហៅ លី រួចខ្លួនពីការចោទប្រកាន់ខាងលើតាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសាលាដំបូងខេត្តកោះកុង

## វិនិច្ឆ័យសេចក្តី

១/-ឱ្យ: ឈ្មោះ [redacted] វុត្ថា ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] តុលា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] ប៊ុនថាំ ហៅប៉ិត ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] ថាវ ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] សើគីរីន ហៅលីន ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ រួចខ្លួន ពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ និងមានមនុស្សច្រើនក្នុងឋានៈជាចារី និងសហចារី ប្រព្រឹត្តនៅចំណុចសួនច្បារមាត់សមុទ្រ ភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២១៨ ចំណុច២,៣ នៃក្រមព្រហ្មទណ្ឌ និងតាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២/-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វុត្ថា ឈ្មោះ [redacted] តុលា ឈ្មោះ [redacted] ប៊ុនថាំ ហៅប៉ិត ឈ្មោះ [redacted] ថាវ និងឈ្មោះ [redacted] សើគីរីន ហៅលីន និងចំពោះមុខ



Scanned with CamScanner

មេធាវីការពារជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វុត្ថា ឈ្មោះ [redacted] គុណា , ឈ្មោះ [redacted] ប៊ុនថាំ ហៅប៉េត , ឈ្មោះ [redacted] ថាវ និងឈ្មោះ [redacted] សេរីគីរីន ហៅលីន និងតំណាងមុខមេធាវីការពារជនជាប់ចោទ ។

-បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃព្រហស្បតិ៍ ០៩រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

កោះកុង, ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ក្រឡាបញ្ជីសវនាការ

[redacted]

[redacted]